រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ **សមាគមប្រតិបត្តិករទូរគមនាគមន៍នៅព្រះរាជាណាចក្រកម្ពុជា** ("**ស.ប.ទ.ក**") បានចុះបញ្ជីត្រឹមត្រូវជាមួយក្រសួងមហាផ្ទៃស្របតាមច្បាប់នៃប្រទេសកម្ពុជា។ **ស.ប.ទ.ក** មានទីស្នាក់ការនៅអាគារពាណិជ្ជកម្មសូម៉ា ជាន់ទី៥ ផ្ទះលេខ២សេ ផ្លូវ១២០ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**ស.ប.ទ.ក** ត្រូវបានបង្កើតឡើងដោយសមាជិកស្ថាបនិកចំនួនបួន៖ ក្រុមហ៊ុន **ស្មាត អាស្យាតា ខូអិលធីឌី** ក្រុមហ៊ុន **ខេម ជី អេស អេម អែលធីឌី** ក្រុមហ៊ុន **វៀតធេល (ខេមបូឌា)** និងក្រុមហ៊ុន **សៅ អ៊ីស្ត អេស៊ា ធេលីខម (ខេមបូឌា)**។ **ស.ប.ទ.ក** បើកទទួលក្រុមហ៊ុនប្រតិបត្តិករទូរគមនាគមន៍ដទៃទៀតដើម្បីចូលរួមជាសមាជិករបស់ខ្លួនផងដែរ។

សមាជិកស្ថាបនិក បានតែងតាំងគណៈកម្មការប្រតិបត្តិ ដើម្បីជានានូវកិច្ចដំណើរការប្រចាំថ្ងៃរបស់សមាគម។ គណៈកម្មការប្រតិបត្តិ ត្រូវបានដឹកនាំដោយលោក **លី តៃសេង** ជាប្រធាន។

**ស.ប.ទ.ក** មានគោលបំណង និងគោលដៅសំខាន់ៗ ធ្វើជាអ្នកតំណាងស្របច្បាប់ឱ្យសមាជិករបស់ខ្លួន ក្នុងការទាក់ទងជាមួយតួអង្គដទៃទៀតនៅក្នុងវិស័យឯកជន និងសាធារណៈ ការចែករំលែក និងការផ្លាស់ប្តូរគំនិត និងព័ត៌មាន ការធ្វើបច្ចុប្បន្នភាពអំពីច្បាប់ និងបទប្បញ្ញត្តិ ការលើកឡើង និងការសម្តែងមតិពីការព្រួយបារម្ភរបស់សមាជិកខ្លួន ព្រមទាំងការផ្តល់យោបល់ និងការគាំទ្រដល់សមាជិករបស់ខ្លួន សម្រាប់កិច្ចដំណើរការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា និងដើម្បីចូលរួមចំណែកបន្ថែម ទៀតក្នុងការអភិវឌ្ឍនៃឧស្សាហកម្មទូរគមនាគមន៍។

បេសកកម្មរបស់ **ស.ប.ទ.ក** គឺដើម្បីលើកកម្ពស់ឋានៈរបស់ឧស្សាហកម្មទូរគមនាគមន៍ក្នុងភាពជាដៃគូដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការខិតខំប្រឹងប្រែងធ្វើឌីជីថលភាវូបនីយកម្មនៃសេដ្ឋកិច្ចជាតិ ស្របតាមទិសដៅដែលបានកំណត់ដោយយុទ្ធសាស្ត្រចតុកោណ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ **ស.ប.ទ.ក** បានធ្វើមហាសន្និបាតវិសាមញ្ញលើកដំបូងរបស់ខ្លួន ដើម្បីចាប់ផ្តើមប្រតិបត្តិការរបស់សមាគម។

សម្រាប់សំនួរផ្សេងៗអំពី **ស.ប.ទ.ក** សូមទាក់ទងមកលោក **លី តៃសេង** តាមរយៈទូរស័ព្ទលេខ +៨៥៥ (០)២៣ ២២៤ ៣៣៧ ឬតាមរយៈអ៊ីម៉ែល tayseng@hbslaw.asia។